(អត្ថបទនេះជំនួសទំព័រ១០ ដល់ ទំព័រ ២១ នៃអត្ថបទ ដែលពីមុនចាត់ថ្នាក់ក្នុងកូដ លេខ២-00៩)

# អង្គការកម្មសិទ្ធិបញ្ញាពិភពលោក( WIPO )

## បទបញ្ជានៃសន្ធិសញ្ញាទីក្រុងប៊ុយដាប៉េស ស្តីពីការទទួលស្គាល់ជាអន្តរជាតិការ តម្កល់មីក្រូសារីរាង្គសម្រាប់ គោលបំណង នីតិវិធីប្រកាសនីយបត្រតក្កកម្ម[*]

(អនុម័តចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧ ហើយ បានធ្វើវិសោធនកម្មចុះ ថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៨១ និង ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០០២)

### មាតិកា[**]


| | ប្រការ |
|---|---|
| ពាក្យបំព្រួញ និង ការបកស្រាយពាក្យ "ការចុះហត្ថលេខា"...................... | ១ |
| "សន្ធិសញ្ញា"........................................................................ | ១.១ |
| "មាត្រា" ........................................................................ | ១.២ |
| "ការចុះហត្ថលេខា"................................................................ | ១.៣ |
| អាជ្ញាធរតម្កល់អន្តរជាតិ........................................................... | ២ |
| ឋានៈផ្លូវច្បាប់.................................................................... | ២.១ |
| បុគ្គលិក និង សម្ភារៈបរិក្ខារ.................................................... | ២.២ |
| ការផ្តល់គំរូ..................................................................... | ២.៣ |
| ការទទួលបានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ.................................... | ៣ |
| សេចក្តីជូនដំណឹង.............................................................. | ៣.១ |
| ដំណើរការនៃសេចក្តីជូនដំណឹង.................................................. | ៣.២ |
| ការពង្រីកបញ្ជីប្រភេទមីក្រូសរីរាង្គដែលទទួលយក...................... | ៣.៣ |
| ការបញ្ចប់ ឬ ការកម្រិតឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ......................... | ៤ |
| សំណើ ដំណើរការនៃសំណើ.................................................... | ៤.១ |
| សេចក្តីជូនដំណឹង កាលបរិច្ឆេទអានុភាព ដំណើរការនៃសេចក្តីជូនដំណឹង..................................................... | ៤.២ |

វិបាកនៃការតម្កល់........................................................................ ៤.៣
ការខកខានមិនបានបំពេញកាតព្វកិច្ចដោយអាជ្ញាធរតម្កល់អន្តរជាតិ........ ៥
ការឈប់បំពេញមុខងារទាក់ទងនឹងមីក្រូសរីរាង្គដែលបានតម្កល់... ៥.១
ការបដិសេធទទួលយកប្រភេទមីក្រូសរីរាង្គមួយចំនួន.................. ៥.២
ការតម្កល់ដើម ឬ ការតម្កល់ជាថ្មី.......................................................... ៦
ការតម្កល់ដើម........................................................................... ៦.១
ការតម្កល់ជាថ្មី.......................................................................... ៦.២
លក្ខខណ្ឌនៃអាជ្ញាធរតម្កល់អន្តរជាតិ......................................... ៦.៣
នីតិវិធីទទួលយក..................................................................... ៦.៤
បង្កាន់ដៃ............................................................................................ ៧
ការចេញបង្កាន់ដៃ.................................................................... ៧.១
ទម្រង់ ភាសា ការចុះហត្ថលេខា................................................. ៧.២
មាតិកាក្នុងការតម្កល់ដើម......................................................... ៧.៣
មាតិកាក្នុងការតម្កល់ជាថ្មី......................................................... ៧.៤
បង្កាន់ដៃក្នុងករណីផ្ទេរ............................................................ ៧.៥
ការជូនដំណឹងពីសេចក្តីអធិប្បាយបែបវិទ្យាសាស្រ្ត
និង/ឬ សំណើកំណត់ចំណាត់ថ្នាក់........................................... ៧.៦
ការបង្ហាញពេលក្រោយឬវិសោធនកម្មសេចក្តីអធិប្បាយបែបវិទ្យា
សាស្រ្តនិង/ឬ សំណើកំណត់ចំណាត់ថ្នាក់.......................................... ៨
សេចក្តីជូនដំណឹង................................................................. ៨.១
ការបញ្ជាក់.......................................................................... ៨.២
ការរក្សាទុកមីក្រូសរីរាង្គ...................................................................... ៩
រយៈពេលរក្សាទុក................................................................. ៩.១
ការសម្ងាត់.......................................................................... ៩.២
តែស្តនិងសេចក្តីអះអាងស្តីពីភាពមានជីវិត....................................... ១០
កាតព្វកិច្ចធ្វើតែស្ត................................................................ ១០.១
សេចក្តីអះអាងស្តីពីភាពមានជីវិត.......................................... ១០.២
ការផ្តល់គំរូ......................................................................................... ១១
ការផ្តល់គំរូដល់ការិយាល័យកម្មសិទ្ធិឧស្សាហកម្មពាក់

ព័ន្ធ.......................................................................................... ១១.១
ការផ្តល់គំរូដល់ ឬដោយមានការអនុញ្ញាតពីអ្នកតម្កល់.............. ១១.២
ការផ្តល់គំរូដល់ភាគីដែលមានសិទ្ធស្របច្បាប់.......................... ១១.៣
ប្រការរួម........................................................................................ ១១.៤
កាផ្លាស់ប្តូរក្នុងមាត្រា១១.១ និងមាត្រា ១១.៣ ពេលដាក់
សំណុំលិខិតស្នើសុំអន្តរជាតិ................................................. ១១.៥
កម្រៃ............................................................................................... ១២
ប្រភេទនិងចំនួន......................................................................... ១២.១
ការផ្លាស់ប្តូរចំនួន....................................................................... ១២.២
ការគណនារយៈពេល...................................................................... ១២ ស្ទួន
រយៈពេលគិតជាឆ្នាំ.................................................................. ១២ស្ទួន.១
រយៈពេលគិតជាខែ.................................................................. ១២ស្ទួន.២
រយៈពេលគិតជាថ្ងៃ.................................................................. ១២ស្ទួន.៣
ការបោះពុម្ពផ្សាយដោយការិយាល័យអន្តរជាតិ................................ ១៣
ទម្រង់នៃការបោះពុម្ពផ្សាយ..................................................... ១៣.១
មាតិកា........................................................................................ ១៣.២
ការចំណាយរបស់គណៈប្រតិភូ........................................................ ១៤
មុខចំណាយ................................................................................ ១៤.១
ការខ្វះកូរ៉ុមក្នុងសន្និបាត............................................................. ១៥
ការបោះឆ្នោតពីចម្ងាយ............................................................. ១៥.១

## ប្រការ ១
## ពាក្យបំព្រួញ និង ការបកស្រាយពាក្យ "ការចុះហត្ថលេខា"
### ១.១ "សន្ធិសញ្ញា"

ក្នុងបទបញ្ញាទាំងនេះ ពាក្យ "សន្ធិសញ្ញា" សំដៅដល់ សន្ធិសញ្ញាទីក្រុង ប៊ុយដាប៉េសស្តីពីការទទួលស្គាល់ជាអន្តរជាតិការតម្កល់មីក្រូសរីរាង្គសម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្ម[1]។

### ១.២ "មាត្រា"

ក្នុងបទបញ្ញាទាំងនេះ ពាក្យ មាត្រា សំដៅដល់មាត្រាជាក់លាក់ណាមួយនៃសន្ធិសញ្ញា។

### ១.៣ "ការចុះហត្ថលេខា"

ក្នុងបទបញ្ញាទាំងនេះ នៅពេលណាដែល ពាក្យ "ការចុះហត្ថលេខា" ត្រូវបានប្រើ ត្រូវយល់ថា នៅពេលដែលច្បាប់រដ្ឋ ដែលអាជ្ញាធរតម្កល់អន្តរជាតិតាំងនៅ ទាមទារឱ្យប្រើត្រា ជួសការចុះហត្ថលេខា ពាក្យនេះ ត្រូវមានន័យថា " ត្រា " សម្រាប់គោលបំណងនៃអាជ្ញាធរនេះ។

## ប្រការ ២
## អាជ្ញាធរតម្កល់អន្តរជាតិ
### ២.១ ឋានៈផ្លូវច្បាប់

អាជ្ញាធរតម្កល់អន្តរជាតិ អាចជាភ្នាក់ងាររដ្ឋាភិបាល រួមមានស្ថាប័នសាធារណៈណាមួយដែលភ្ជាប់ទៅនឹងរដ្ឋបាលសាធារណៈក្រៅពីរដ្ឋាភិបាលកណ្តាលឬស្ថាប័នឯកជន។

### ២.២ បុគ្គលិក និងសម្ភារៈបរិក្ខារ

លក្ខខណ្ឌដូចមានចែងក្នុងមាត្រា៦(២)(ii) ត្រូវបញ្ចូលជាពិសេសដូចខាងក្រោម:

(i) បុគ្គលិក និងសម្ភារៈបរិក្ខាររបស់អាជ្ញាធរតម្កល់អន្តរជាតិ ដែលអាចឱ្យអាជ្ញាធរនេះអាចរក្សាទុកមីក្រូសរីរាង្គដែលបានតម្កល់ ក្នុងលក្ខណៈដែលធានាបានថាមីក្រូសរីរាង្គទាំងនេះត្រូវបានរក្សាឱ្យនៅមានជីវិត និងមិនខូចគុណភាព

(ii) ចំពោះការរក្សាទុកមីក្រូសរីរាង្គ អាជ្ញាធរតម្កល់អន្តរជាតិណាមួយ ត្រូវចែងពីវិធានសុវត្ថិភាពគ្រប់គ្រាន់ដើម្បីបន្ថយហានិភ័យជាអប្បបរមានៃការបាត់បង់មីក្រូសរីរាង្គដែលបានតម្កល់ ជាមួយអាជ្ញាធរ ។

### ២.៣ ការផ្តល់គំរូ

លក្ខខណ្ឌដូចមានចែងក្នុងមាត្រា៦(២)(viii) ត្រូវបញ្ចូលជាពិសេសលក្ខខណ្ឌដែលអាជ្ញាធរតម្កល់អន្តរជាតិត្រូវផ្តល់គំរូមីក្រូសរីរាង្គដែលបានតម្កល់ ឱ្យបានរហ័សនិងត្រឹមត្រូវ។

## ប្រការ ៣

## ការទទួលបានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ

### ៣.១ សេចក្តីជូនដំណឹង

(ក) សេចក្តីជូនដំណឹងដូចមានចែងក្នុងមាត្រា៧(១) ត្រូវដាក់ទៅអគ្គនាយក បើជារដ្ឋហត្ថលេខី ត្រូវដាក់តាមបណ្តាញការទូត ឬ បើជាអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ត្រូវដាក់តាមនាយកមន្ត្រីប្រតិបត្តិរបស់ខ្លួន។

(ខ) សេចក្តីជូនដំណឹងត្រូវៈ

(i) បង្ហាញឈ្មោះនិងអាសយដ្ឋានស្ថាប័នតម្កល់ដែលពាក់ព័ន្ធនឹងសេចក្តីជូនដំណឹង

(ii) មានព័ត៌មានលម្អិតដូចជាសមត្ថភាពរបស់ស្ថាប័នដើម្បីគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៦(២) រួមទាំងព័ត៌មានស្តីពីឋានៈផ្លូវច្បាប់ កម្រិតផ្នែកវិទ្យាសាស្ត្រ បុគ្គលិកនិងសម្ភារៈបរិក្ខាររបស់ខ្លួន

(iii) បញ្ជាក់ប្រភេទទាំងនេះ នៅពេលដែលស្ថាប័នតម្កល់នេះ ចង់ទទួលយកការតម្កល់តែប្រភេទ មីក្រូសរីរាង្គមួយចំនួន

(iv) បង្ហាញចំនួនកម្រៃណាមួយ ដែលស្ថាប័ននេះនឹងយកឈ្នួលលើការរក្សាទុក សេចក្តីអះអាងស្តីពីភាពមានជីវិត និងការផ្តល់គំរូមីក្រូសរីរាង្គបន្ទាប់ពីទទួលបានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ

(v) បង្ហាញភាសាផ្លូវការ ឬ ភាសានៃស្ថាប័ននេះ

(vi) នៅពេលដែលអាចអនុវត្តបាន បង្ហាញកាលបរិច្ឆេទដូចមានចែងក្នុងមាត្រា៧(១)(ខ)។

### ៣.២ ដំណើរការនៃសេចក្តីជូនដំណឹង

ប្រសិនបើសេចក្តីជូនដំណឹង គោរពតាមមាត្រា៧(១) និង ប្រការ៣.១ អគ្គនាយកត្រូវជូនដំណឹងភ្លាមទៅរដ្ឋហត្ថលេខីនិងអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលទាំងអស់ ហើយការិយាល័យអន្តរជាតិត្រូវបោះពុម្ពផ្សាយភ្លាម។

### ៣.៣ ការពង្រីកបញ្ជីប្រភេទមីក្រូសរីរាង្គដែលទទួលយក

រដ្ឋហត្ថលេខី ឬ អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ដែលបានធ្វើសេចក្តីជូនដំណឹងដូចមានចែងក្នុងមាត្រា៧(១) នៅពេលណាមួយបន្ទាប់មក អាចជូនដំណឹងទៅអគ្គនាយកថាការធានារបស់ខ្លួនត្រូវបានពង្រីកចំពោះប្រភេទមីក្រូសរីរាង្គជាក់លាក់ ដែលមិនបានពង្រីកពីមុន។ ក្នុងករណីនេះ ហើយចំពោះប្រភេទមីក្រូសរីរាង្គបន្ថែមនេះ មាត្រា៧និង ប្រការ៣.១និងប្រការ៣.២ ត្រូវអនុវត្តដូចគ្នាផងដែរ។

## ប្រការ ៤

## ការបញ្ចប់ ឬ ការកម្រិតឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ

## ៤.១ សំណើ ដំណើរការសំណើ

(ក) សំណើដូចមានចែងក្នុងមាត្រា៨(១)(ក) ត្រូវដាក់ជូនអគ្គនាយកដូចមានចែងក្នុងប្រការ៣.១(ក)។

(ខ) សំណើត្រូវ:

(i) បង្ហាញឈ្មោះ និងអាសយដ្ឋានអាជ្ញាធរតម្កល់អន្តរជាតិដែលពាក់ព័ន្ធ

(ii) បញ្ជាក់ប្រភេទទាំងនេះ នៅពេលដែលសំណើទាក់ទងតែប្រភេទមីក្រូសរីរាង្គមួយចំនួន

(iii) បង្ហាញលម្អិតពីអង្គហេតុដែលជាមូលដ្ឋាននៃសំណើ។

(គ) ប្រសិនបើសំណើគោរពតាមកថាខណ្ឌ(ក)និង(ខ) អគ្គនាយកត្រូវជូនដំណឹងអំពីសំណើនេះភ្លាមទៅរដ្ឋហត្ថលេខីនិងអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលទាំងអស់។

(ឃ) យោងតាមកថាខណ្ឌ(ង) សន្និបាតត្រូវពិចារណាលើសំណើ ក្រោយរយៈពេល ៦(ប្រាំមួយ)ខែនិងមុនរយៈពេល៨(ប្រាំបី)ខែ រាប់ចាប់ពីការជូនដំណឹងពីសំណើ។

(ង) តាមយោបល់របស់អគ្គនាយក នៅពេលដែលរយៈពេលដូចមានចែងក្នុងកថាខណ្ឌ(ឃ) អាចបង្កគ្រោះថ្នាក់ដល់ផលប្រយោជន៍អ្នកតម្កល់ពិតប្រាកដឬអ្នកតម្កល់សក្តានុពល អគ្គនាយកអាចកោះប្រជុំសន្និបាត តាមកាលបរិច្ឆេទមុនកាលបរិច្ឆេទផុតកំណត់រយៈពេល ៦(ប្រាំមួយ)ខែ ដូចមានចែងក្នុងកថាខណ្ឌ(ឃ)។

(ច) ប្រសិនបើ សន្និបាតសម្រេចបញ្ចប់ឬកម្រិត ប្រភេទមីក្រូសរីរាង្គមួយចំនួនឋានៈអាជ្ញាធរតម្កល់អន្តរជាតិ សេចក្តីសម្រេចនេះត្រូវមានអានុភាពអនុវត្ត ៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទធ្វើសេចក្តីសម្រេច។

## ៤.២ សេចក្តីជូនដំណឹង កាលបរិច្ឆេទអានុភាព ដំណើរការនៃសេចក្តីជូនដំណឹង

(ក) សេចក្តីជូនដំណឹងដូចមានចែងក្នុងមាត្រា៨(២)(ក) ត្រូវដាក់ជូនអគ្គនាយកដូចមានចែងក្នុងប្រការ៣.១(ក)។

(ខ) សេចក្តីជូនដំណឹងត្រូវៈ

(i) បង្ហាញឈ្មោះនិងអាសយដ្ឋានអាជ្ញាធរតម្កល់អន្តរជាតិ ដែលពាក់ព័ន្ធ

(ii) បញ្ជាក់ប្រភេទទាំងនេះ នៅពេលដែលសេចក្តីជូនដំណឹងទាក់ទងតែប្រភេទមីក្រូសរីរាង្គមួយចំនួន

(iii) បង្ហាញកាលបរិច្ឆេទក្រោយនេះ នៅពេលដែលរដ្ឋហត្ថលេខី ឬ អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ដែលធ្វើសេចក្តីជូនដំណឹង ចង់ឱ្យមានអានុភាពដូចមានចែងក្នុងមាត្រា៨(២)(ខ) តាមកាលបរិច្ឆេទ ក្រោយផុតកំណត់រយៈពេល៣(បី)ខែរាប់ចាប់ពីកាលបរិច្ឆេទនៃសេចក្តីជូនដំណឹង

(គ) នៅពេលដែលកថាខណ្ឌ(ខ)(iii) អនុវត្ត អានុភាពដូចមានចែងក្នុងមាត្រា៨(២)(ខ) ត្រូវមានតាមកាលបរិច្ឆេទដែលបានបង្ហាញក្នុងកថាខណ្ឌនោះក្នុងសេចក្តីជូនដំណឹង។ បើមិនដូច្នោះទេ អានុភាពត្រូវមាននៅពេលផុតកំណត់៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទនៃសេចក្តីជូនដំណឹង។

(ឃ) អគ្គនាយកត្រូវជូនដំណឹងភ្លាមទៅរដ្ឋហត្ថលេខីនិងអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលទាំងអស់ អំពីការទទួលបានសេចក្តីជូនដំណឹងណាមួយតាមមាត្រា៨(២) និងអំពីកាលបរិច្ឆេទអានុភាពតាមកថាខណ្ឌ(គ)។ ការិយាល័យអន្តរជាតិត្រូវបោះពុម្ពផ្សាយកំណត់ដែលទាក់ទងភ្លាម។

### ៤.៣ វិបាកនៃការតម្កល់

ក្នុងករណីមានការបញ្ចប់ ឬ ការកម្រិតឋានៈអាជ្ញាធរតម្កល់អន្តរជាតិ តាមមាត្រា៨(១) មាត្រា៨(២) មាត្រា៩(៤) ឬមាត្រា១៧(៤) ប្រការ៥.១ ត្រូវអនុវត្តដូចគ្នាផងដែរ។

## ប្រការ ៥

## ការខកខានមិនបានបំពេញកាតព្វកិច្ចដោយអាជ្ញាធរតម្កល់អន្តរជាតិ

### ៥.១ ការឈប់បំពេញមុខងារទាក់ទងនឹងមីក្រូសរីរាង្គដែលបានតម្កល់

(ក) ប្រសិនបើអាជ្ញាធរតម្កល់អន្តរជាតិណាមួយ ឈប់បំពេញការងារណាមួយ ជាបណ្តោះអាសន្នឬជាស្ថាពរ ដែលខ្លួនគួរបំពេញតាមសន្ធិសញ្ញានិងបទបញ្ជាទាំងនេះ ទាក់ទងនឹងមីក្រូសរីរាង្គណាមួយ ដែលបានតម្កល់ជាមួយខ្លួន ទាក់ទងនឹងអាជ្ញាធរនេះ រដ្ឋហត្ថលេខី ឬ អង្គការសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាល ដែលបានផ្តល់ការធានាតាមមាត្រា៦(១) ត្រូវៈ

(i) ធានាឱ្យអស់ពីលទ្ធភាព ថា គំរូមីក្រូសរីរាង្គទាំងអស់នេះ ត្រូវបានផ្ទេរភ្លាម ដោយគ្មានធ្វើឱ្យខូចខាត ឬធ្វើឱ្យខូចគុណភាពគំរូទាំងនេះ ពីអាជ្ញាធរនេះ ("អាជ្ញាធរខកខានមិនបានបំពេញកាតព្វកិច្ច") ទៅអាជ្ញាធរតម្កល់អន្តរជាតិមួយផ្សេងទៀត ("អាជ្ញាធរជំនួស")

(ii) ធានាឱ្យអស់ពីលទ្ធភាព ថា សំបុត្រ ឬសេចក្តីជូនដំណឹងផ្សេងទៀតទាំងអស់ដែលដាក់ជូនអាជ្ញាធរខកខានមិនបានបំពេញកាតព្វកិច្ចនិងសំណុំឯកសារ និង ព័ត៌មានដែលពាក់ព័ន្ធផ្សេងទៀតដែលអាជ្ញាធរនេះកាន់កាប់ ទាក់ទងនឹងមីក្រូសរីរាង្គនេះ ត្រូវបានផ្ទេរភ្លាមទៅអាជ្ញាធរជំនួស

(iii) ធានាឱ្យអស់ពីលទ្ធភាព ថាអាជ្ញាធរខកខានមិនបានបំពេញកាតព្វកិច្ច ជូនដំណឹងភ្លាមទៅអ្នកតម្កល់ទាំងអស់ ដែលប៉ះពាល់ដោយការឈប់បំពេញមុខងារនិងជូនដំណឹងពីការផ្ទេរ

(iv) ជូនដំណឹងភ្លាម ទៅអគ្គនាយកពីអង្គហេតុ និងកម្រិតនៃការឈប់បំពេញមុខងារនេះ និង ការចាត់វិធានការរបស់រដ្ឋហត្ថលេខី ឬ អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលនេះតាមចំនុច(i) ដល់ (ii)

(ខ) អគ្គនាយកត្រូវជូនដំណឹងភ្លាមទៅរដ្ឋហត្ថលេខីនិងអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលទាំងឡាយ ក៏ដូចជា ការិយាល័យកម្មសិទ្ធិឧស្សាហកម្មពីការទទួលបានសេចក្តីជូនដំណឹងតាមកថាខណ្ឌ(ក)(iv)។ការិយាល័យអន្តរជាតិ ត្រូវបោះពុម្ពផ្សាយភ្លាមនូវសេចក្តីជូនដំណឹងរបស់អគ្គនាយក និងសេចក្តីជូនដំណឹងដែលទទួលបានដោយអគ្គនាយក ។

(គ) តាមនីតិវិធីប្រកាសនីយបត្រតក្កកម្មដែលអនុវត្ត អាចតម្រូវឱ្យអ្នកតម្កល់ត្រូវជូនដំណឹងភ្លាម បន្ទាប់ពីទទួលបានបង្កាន់ដៃដូចមានចែងក្នុងប្រការ៧.៥ ទៅការិយាល័យកម្មសិទ្ធិឧស្សាហកម្មណាមួយ ដែលសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មបានដាក់ដោយយោងទៅការតម្កល់មុន នូវលេខរៀងថ្មីដែលផ្តល់ឱ្យការតម្កល់ដោយអាជ្ញាធរជំនួស ។

(ឃ) អាជ្ញាធរជំនួស ត្រូវរក្សាទុកក្នុងទម្រង់ដ៏សមស្របនូវលេខរៀងដែលផ្តល់ឱ្យដោយអាជ្ញាធរខកខានមិនបានបំពេញកាតព្វកិច្ច រួមជាមួយនឹងលេខរៀងថ្មី។

(ង) បន្ថែមលើការផ្ទេរដែលបានធ្វើតាមកថាខណ្ឌ(ក)(i) តាមសំណើរបស់អ្នកតម្កល់អាជ្ញាធរខកខានមិនបានបំពេញកាតព្វកិច្ច ត្រូវផ្ទេរតាមតែអាចធ្វើទៅបាននូវគំរូមីក្រូសរីរាង្គណាមួយដែលបានតម្កល់ជាមួយខ្លួន រួមជាមួយច្បាប់ចម្លងនៃសំបុត្រ ឬសេចក្តីជូនដំណឹង

ផ្សេងទៀតទាំងអស់និងច្បាប់ចម្លងនៃសំណុំឯកសារនិងព័ត៌មានពាក់ព័ន្ធផ្សេងទៀតទាំងអស់ដូចមានចែងក្នុងកថាខណ្ឌ(ក)(ii) ទៅអាជ្ញាធរតម្កល់អន្តរជាតិណាមួយដែលបង្ហាញដោយអ្នកតម្កល់ ក្រៅពីអាជ្ញាធរជំនួស ឱ្យតែអ្នកតម្កល់ទូទាត់ការចំណាយទៅអាជ្ញាធរខកខានមិនបានបំពេញកាតព្វកិច្ចពីការផ្ទេរនេះ។ អ្នកតម្កល់ត្រូវបង់កម្រៃចំពោះការរក្សាទុកគំរូនេះទៅអាជ្ញាធរតម្កល់អន្តរជាតិដែលអ្នកតម្កល់បានបង្ហាញ។

(ង) តាមសំណើរបស់អ្នកតម្កល់ដែលរងការប៉ះពាល់ អាជ្ញាធរខកខានមិនបានបំពេញកាតព្វកិច្ចត្រូវរក្សាទុកគំរូមីក្រូសរីរាង្គដែលបានតម្កល់ជាមួយខ្លួន តាមតែអាចធ្វើទៅបាន។

### ៥.២ ការបដិសេធទទួលយកប្រភេទមីក្រូសរីរាង្គមួយចំនួន

(ក) ប្រសិនបើ អាជ្ញាធរតម្កល់អន្តរជាតិណាមួយ បដិសេធមិនទទួលការតម្កល់ប្រភេទមីក្រូសរីរាង្គណាមួយ ដែលគួរទទួលតាមការធានាដែលបានផ្តល់ ទាក់ទងនឹងអាជ្ញាធរនេះ រដ្ឋហត្ថលេខី ឬ អង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលដែលបានធ្វើសេចក្តីប្រកាសដូចមានចែងក្នុងមាត្រា៧(១)(ក) ត្រូវជូនដំណឹងភ្លាមទៅអគ្គនាយកពីអង្គហេតុនិងការចាត់វិធានការពាក់ព័ន្ធ។

(ខ) អគ្គនាយក ត្រូវជូនដំណឹងភ្លាម ទៅរដ្ឋហត្ថលេខីនិងអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលផ្សេងទៀត ពីសេចក្តីជូនដំណឹងដែលទទួលបានតាមកថាខណ្ឌ(ក) ។ ការិយាល័យអន្តរជាតិ ត្រូវបោះពុម្ពផ្សាយភ្លាមនូវសេចក្តីជូនដំណឹងរបស់អគ្គនាយកនិងសេចក្តីជូនដំណឹងដែលទទួលបានដោយអគ្គនាយក។

## ប្រការ ៦

## ការតម្កល់មុន ឬ ការតម្កល់ជាថ្មី

### ៦.១ ការតម្កល់មុន

(ក) យោងតាមការអនុវត្តន៍ប្រការ ៦.២ មីក្រូសរីរាង្គដែលបានបញ្ជូនដោយអ្នកតម្កល់ទៅអាជ្ញាធរតម្កល់អន្តរជាតិត្រូវអមដោយសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរ ដែលមានចុះហត្ថលេខាអ្នកតម្កល់ និង មាន:

(i) ការបង្ហាញថា ការតម្កល់ត្រូវបានធ្វើឡើងតាមសន្ធិសញ្ញានេះ និងសន្យាមិនដកមីក្រូសរីរាង្គនេះក្នុងរយៈពេលដូចកំណត់ក្នុងប្រការ៩.១

(ii) ឈ្មោះ និង អាសយដ្ឋានអ្នកតម្កល់

(iii) លក្ខខណ្ឌលម្អិតដែលចាំបាច់ចំពោះការចិញ្ចឹមមីក្រូសរីរាង្គ ចំពោះការរក្សាទុកនិងចំពោះការធ្វើតេស្តពីភាពមានជីវិត និង នៅពេលដែលបន្សំ

មីក្រូសរីរាង្គត្រូវបានតម្កល់ សេចក្តីអធិប្បាយធាតុនៃបន្សំនេះ ហើយយ៉ាងហោចណាស់វិធីមួយដែលអនុញ្ញាតិឱ្យពិនិត្យពីវត្តមានមីក្រូសរីរាង្គទាំងនេះ

(iv) អត្តសញ្ញាណយោង(លេខ និមិត្តសញ្ញា ។ល។ ) ដែលអ្នកតម្កល់បានផ្តល់ឱ្យចំពោះមីក្រូសរីរាង្គ

(v) ការបង្ហាញពីលក្ខណៈមីក្រូសរីរាង្គដែលគ្រោះថ្នាក់ ឬអាចគ្រោះថ្នាក់ដល់សុខភាពឬបរិស្ថាន ឬ ការបង្ហាញថាអ្នកតម្កល់មិនបានដឹងពីលក្ខណៈទាំងនេះ។

(ខ) គួរឱ្យមានសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងកថាខណ្ឌ(ក) ដែលគួរមានសេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬសំណើកំណត់ចំណាត់ថ្នាក់ មីក្រូសរីរាង្គដែលបានតម្កល់។

## ៦.២ ការតម្កល់ជាថ្មី

(ក) លើកលែងតែកថាខណ្ឌ(ខ) ក្នុងករណីការតម្កល់ជាថ្មីធ្វើឡើងតាមមាត្រា៤ មីក្រូសរីរាង្គដែលបានបញ្ជូនដោយអ្នកតម្កល់ទៅអាជ្ញាធរតម្កល់អន្តរជាតិ ត្រូវអមដោយច្បាប់ចម្លងនៃបង្កាន់ដៃការតម្កល់មុន អមដោយច្បាប់ចម្លងនៃសេចក្តីថ្លែងថ្មីបំផុតទាក់ទងនឹងភាពមានជីវិតនៃមីក្រូសរីរាង្គដែលជាកម្មវត្ថុនៃការតម្កល់មុន ហើយបញ្ជាក់ថាមីក្រូសរីរាង្គនេះនៅមានជីវិត និងអមដោយសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរដែលមានការចុះហត្ថលេខារបស់អ្នកតម្កល់និង មាន:

(i) ការបង្ហាញដូចមានចែងក្នុងប្រការ៦.១ (ក) (i) ដល់ (v)

(ii) សេចក្តីប្រកាសដែលបញ្ជាក់ពីមូលហេតុពាក់ព័ន្ធតាមមាត្រា៤(១)(ក) នៃការតម្កល់ជាថ្មី សេចក្តីថ្លែងដែលអះអាងថាមីក្រូសរីរាង្គដែលជាកម្មវត្ថុនៃការតម្កល់ជាថ្មីនេះ គឺដូចគ្នាទៅនឹងកម្មវត្ថុនៃការតម្កល់មុន និងការបង្ហាញកាលបរិច្ឆេទ ដែលអ្នកតម្កល់បានទទួលសេចក្តីជូនដំណឹងដូចមានចែងក្នុងមាត្រា៤(១)(ក) ឬ កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយដូចមានចែងក្នុងមាត្រា៤(១)(ង) តាមករណីនីមួយៗ

(iii) សេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬសំណើកំណត់ចំណាត់ថ្នាក់ថ្មីបំផុត ដូចដែលបានជូនដំណឹងទៅអាជ្ញាធរតម្កល់អន្តរជាតិដែលការតម្កល់មុនបានធ្វើ នៅពេលដែលសេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬសំណើកំណត់ចំណាត់ថ្នាក់ ត្រូវបង្ហាញទាក់ទងនឹងការតម្កល់មុន ។

(ខ)　នៅពេលដែល ការតម្កល់ជាថ្មី ត្រូវបានធ្វើនៅអាជ្ញាធរតម្កល់អន្តរជាតិដែលបានដាក់តម្កល់ពីមុន កថាខណ្ឌ(ក)(i) មិនត្រូវអនុវត្តទេ។

(គ)　សម្រាប់គោលបំណងនៃកថាខណ្ឌ(ក)និង(ខ) និង ប្រការ៧.៤ ការតម្កល់មុនសំដៅដល់:

(i) ការតម្កល់ថ្មីបំផុតក្នុងចំណោមការតម្កល់ជាថ្មីផ្សេងទៀតទាំងនេះ　នៅពេលដែល　ការតម្កល់ជាថ្មី　ត្រូវបានធ្វើមុនការតម្កល់ជាថ្មីណាមួយផ្សេងទៀត

(ii) ការតម្កល់ដើម នៅពេលដែល ការតម្កល់ជាថ្មីមិនបានធ្វើមុនការតម្កល់ជាថ្មីណាមួយផ្សេងទៀត

## ៦.៣ លក្ខខណ្ឌនៃអាជ្ញាធរតម្កល់អន្តរជាតិ

(ក)　អាជ្ញាធរតម្កល់អន្តរជាតិណាមួយ អាចតម្រូវ:

(i) ថាមីក្រូសរីរាង្គត្រូវតម្កល់ក្នុងទម្រង់និងបរិមាណចាំបាច់ សម្រាប់គោលបំណងនៃសន្ធិសញ្ញានិងបទបញ្ជាទាំងនេះ

(ii) ឱ្យផ្តល់ទម្រង់មួយដែលបង្កើតឡើងដោយអាជ្ញាធរនេះ　និងបំពេញឱ្យបានត្រឹមត្រូវដោយអ្នកតម្កល់សម្រាប់គោលបំណងនីតិវិធិរដ្ឋបាលនៃអាជ្ញាធរនេះ

(iii) ថាសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងប្រការ៦.១(ក) ឬ ប្រការ៦.២(ក) ត្រូវព្រាងក្នុងភាសា ឬ ក្នុងភាសាណាមួយ កំណត់ដោយអាជ្ញាធរនេះ។ ត្រូវយល់ថា សេចក្តីអធិប្បាយលម្អិតនេះត្រូវយ៉ាងហោចណាស់　បញ្ចូលភាសាផ្លូវការ　ឬភាសាដែលបានបង្ហាញតាមប្រការ៣.១(ខ)(v)

(iv) ឱ្យបង់កម្រៃចំពោះការរក្សាទុកដូចមានចែងក្នុងប្រការ១២.១(ក)(i) និង

(v) ថាត្រឹមកម្រិតដែលអនុញ្ញាតដោយច្បាប់ដែលអនុវត្ត អ្នកតម្កល់ត្រូវចុះកិច្ចសន្យាជាមួយអាជ្ញាធរនេះ　ដែលកំណត់អំពីទំនួលខុសត្រូវនៃអ្នកតម្កល់និងអាជ្ញាធរនេះ

(ខ)　អាជ្ញាធរតម្កល់អន្តរជាតិណាមួយត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីលក្ខខណ្ឌនិងវិសោធនកម្មនៃលក្ខខណ្ឌនេះ។

## ៦.៤ នីតិវិធីទទួលយក

(ក)　អាជ្ញាធរតម្កល់អន្តរជាតិ ត្រូវបដិសេធមិនទទួលយកមីក្រូសរីរាង្គណាមួយ

ហើយត្រូវជូនដំណឹងភ្លាមជាលាយលក្ខណ៍អក្សរពីការបដិសេធនិងមូលហេតុនៃការបដិសេធនេះ ទៅអ្នកតម្កល់:

(i) នៅពេលដែល មីក្រូសរីរាង្គមិនមែនជាប្រភេទមីក្រូសរីរាង្គ ដែលបានធានាតាមប្រការ៣.១(ខ)(ii) ឬប្រការ៣.៣

(ii) នៅពេលដែលលក្ខណៈនៃមីក្រូសរីរាង្គខុសប្លែកពីធម្មតា ដែលអាជ្ញាធរតម្កល់អន្តរជាតិ គ្មានបច្ចេកទេសដើម្បីបំពេញការងារ ដែលខ្លួនត្រូវបំពេញតាមសន្ធិសញ្ញានិងបទបញ្ជាទាំងនេះ ទាក់ទងនឹងមីក្រូសរីរាង្គនេះ

(iii) នៅពេលដែល ទទួលបានការតម្កល់ក្នុងលក្ខខណ្ឌដែលបង្ហាញយ៉ាងច្បាស់ថាមានការបាត់មីក្រូសរីរាង្គ ឬ ក្នុងលក្ខខណ្ឌបដិសេធមិនទទួលយកមីក្រូសរីរាង្គដោយមូលហេតុវិទ្យាសាស្ត្រ ។

(ខ) យោងតាមកថាខណ្ឌ(ក) អាជ្ញាធរតម្កល់អន្តរជាតិត្រូវទទួលយកមីក្រូសរីរាង្គណាដែលបានបំពេញលក្ខខណ្ឌទាំងអស់នៃប្រការ៦.១(ក) ឬ ប្រការ៦.២(ក) និង ប្រការ៦.៣(ក)។ ប្រសិនបើមិនបានបំពេញលក្ខខណ្ឌណាមួយ អាជ្ញាធរតម្កល់អន្តរជាតិត្រូវជូនដំណឹងភ្លាមជាលាយលក្ខណ៍អក្សរទៅអ្នកតម្កល់ ពីអង្គហេតុនេះហើយអញ្ជើញអ្នកតម្កល់មកបំពេញលក្ខខណ្ឌទាំងនេះ។

(គ) នៅពេលដែលបានទទួលយកមីក្រូសរីរាង្គ ជាការតម្កល់ដើមឬការតម្កល់ជាថ្មី កាលបរិច្ឆេទនៃការតម្កល់ដើម ឬការតម្កល់ជាថ្មីនេះ ត្រូវជាកាលបរិច្ឆេទដែលអាជ្ញាធរតម្កល់អន្តរជាតិទទួលបានមីក្រូសរីរាង្គនេះ តាមករណីនីមួយៗ។

(ឃ) តាមសំណើរបស់អ្នកតម្កល់និងឱ្យតែបានបំពេញលក្ខខណ្ឌទាំងអស់ដូចមានចែង ក្នុងកថាខណ្ឌ(ខ) អាជ្ញាធរតម្កល់អន្តរជាតិត្រូវចាត់ទុកមីក្រូសរីរាង្គ ដែលបានតម្កល់មុនអាជ្ញាធរនេះទទួលបានឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ ថាបានទទួលតាមកាលបរិច្ឆេទដែលទទួលបានឋានៈនេះ សម្រាប់គោលបំណងនៃសន្ធិសញ្ញានេះ។

## ប្រការ ៧

## បង្កាន់ដៃ

### ៧.១ ការចេញបង្កាន់ដៃ

អាជ្ញាធរតម្កល់អន្តរជាតិត្រូវចេញបង្កាន់ដៃបញ្ជាក់ថាខ្លួនបានទទួលនិងយល់ព្រមទទួលយកមីក្រូសរីរាង្គ ឱ្យអ្នកតម្កល់ ចំពោះការតម្កល់មីក្រូសរីរាង្គនីមួយៗដែលបានផ្ញើឬផ្ទេរមកខ្លួន។

### ៧.២ ទម្រង់ ភាសា ការចុះហត្ថលេខា

(ក) បង្កាន់ដៃណាមួយដូចមានចែងក្នុងប្រការ៧.១ ត្រូវធ្វើឡើងជាទម្រង់មួយដែលហៅថា "ទម្រង់អន្តរជាតិ" ។ គំរូនៃទម្រង់នេះត្រូវបង្កើតអគ្គនាយក ជាភាសានានាដែលសន្និបាតត្រូវកំណត់។

(ខ) ពាក្យឬ អក្សរណាមួយជាអក្សរក្រៅពីអក្សរឡាតាំងត្រូវមានផងដែរក្នុងបង្កាន់ដៃនេះហើយត្រូវបកតាមសំលេងជាអក្ខរក្រមឡាតាំង។

(គ) បង្កាន់ដៃ ត្រូវមានហត្ថលេខាពីបុគ្គលណាមួយដែលមានអំណាចតំណាងអាជ្ញាធរតម្កល់អន្តរជាតិ ឬ ហត្ថលេខាពីមន្ត្រីណាមួយផ្សេងទៀតនៃអាជ្ញាធរ ដែលត្រូវបានអនុញ្ញាតត្រឹមត្រូវដោយបុគ្គលណាមួយនេះ។

## ៧.៣ មាតិកាក្នុងការតម្កល់ដើម

បង្កាន់ដៃណាមួយដូចមានចែងក្នុងប្រការ៧.១ ហើយបានចេញក្នុងករណីនៃការតម្កល់ដើម ត្រូវបង្ហាញថាបង្កាន់ដៃនេះ ចេញដោយស្ថាប័នតម្កល់ក្នុងឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ តាមសន្ធិសញ្ញានេះ និង ត្រូវមានយ៉ាងហោចណាស់ការបង្ហាញដូចខាងក្រោម:

(i) ឈ្មោះ និង អាសយដ្ឋានអាជ្ញាធរតម្កល់អន្តរជាតិ

(ii) ឈ្មោះ និង អាសយដ្ឋានអ្នកតម្កល់

(iii) កាលបរិច្ឆេទការតម្កល់ដើមដូចកំណត់ក្នុងប្រការ៦.៤(គ)

(iv) អត្តសញ្ញាណយោង(លេខ និមិត្តសញ្ញា ។ល។) ដែលអ្នកតម្កល់ផ្តល់ឱ្យចំពោះមីក្រូសរីរាង្គ

(v)លេខរៀងដែលអាជ្ញាធរតម្កល់អន្តរជាតិផ្តល់ឱ្យ ចំពោះការតម្កល់

(vi) ការបញ្ជាក់ពីអង្គហេតុនេះ នៅពេលដែល សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងប្រការ៦.១(ក)មានសេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬ សំណើកំណត់ចំណាត់ថ្នាក់មីក្រូសរីរាង្គ។

## ៧.៤ មាតិកាក្នុងការតម្កល់ជាថ្មី

បង្កាន់ដៃណាមួយដូចមានចែងក្នុងប្រការ៧.១ ហើយបានចេញក្នុងករណីនៃការតម្កល់ជាថ្មីតាមមាត្រា៤ ត្រូវអមដោយច្បាប់ចម្លងនៃបង្កាន់ដៃការតម្កល់ពីមុនមួយច្បាប់(តាមអត្ថន័យនៃប្រការ៦.២(គ)) និងច្បាប់ចម្លងសេចក្តីថ្លែងថ្មីបំផុត មួយច្បាប់ដែលពាក់ព័ន្ធនឹងភាពមានជីវិតនៃមីក្រូសរីរាង្គ ដែលជាកម្មវត្ថុនៃការតម្កល់មុន(តាមអត្ថន័យនៃប្រការ៦.២(គ)) ដែលបង្ហាញថា មីក្រូសរីរាង្គមានជីវិត និងត្រូវមានយ៉ាងហោចណាស់:

(i) ឈ្មោះ និង អាសយដ្ឋានអាជ្ញាធរតម្កល់អន្តរជាតិ

(ii) ឈ្មោះ និង អាសយដ្ឋានអ្នកតម្កល់

(iii) កាលបរិច្ឆេទនៃការតម្កល់ជាថ្មី ដូចកំណត់ក្នុងប្រការ៦.៤(គ)

(iv) អត្តសញ្ញាណយោង(លេខ និមិត្តសញ្ញា ។ល។) ដែលអ្នកតម្កល់ផ្តល់ឱ្យ ចំពោះមីក្រូសរីរាង្គ

(v)លេខរៀងដែលអាជ្ញាធរតម្កល់អន្តរជាតិផ្តល់ឱ្យ ចំពោះការតម្កល់ជាថ្មី

(vi) ការបង្ហាញពីហេតុផលនិងកាលបរិច្ឆេទពាក់ព័ន្ធ ដែលធ្វើឡើង ដោយអ្នកតម្កល់តាមប្រការ៦.២(ក)(ii)

(vii) នៅពេលដែលអនុវត្តប្រការ៦.២(ក)(iii)ការយោងទៅសេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬសំណើកំណត់ចំណាត់ថ្នាក់ ដែលត្រូវបង្ហាញដោយដោយអ្នកតម្កល់

(viii) លេខរៀងដែលផ្តល់ឱ្យការតម្កល់មុន (តាមអត្ថន័យនៃប្រការ៦.២(គ))។

### ៧.៥ បង្កាន់ដៃក្នុងករណីផ្ទេរ

អាជ្ញាធរតម្កល់អន្តរជាតិ ដែលត្រូវបានផ្ទេរគំរូមីក្រូសរីរាង្គ ដូចមានចែងក្នុងប្រការ៥.១(ក)(i) ត្រូវចេញបង្កាន់ដៃដែលបង្ហាញថាបង្កាន់ដៃនេះចេញដោយស្ថាប័នតម្កល់ក្នុងឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិតាមសន្ធិសញ្ញានេះ ដល់អ្នកតម្កល់ ចំពោះការតម្កល់នីមួយៗដែលទាក់ទងនឹងការផ្ទេរគំរូ និងត្រូវមានយ៉ាងហោចណាស់:

(i) ឈ្មោះ និង អាសយដ្ឋានអាជ្ញាធរតម្កល់អន្តរជាតិ

(ii) ឈ្មោះ និង អាសយដ្ឋានអ្នកតម្កល់

(iii) កាលបរិច្ឆេទនៃការផ្ទេរគំរូ ដែលអាជ្ញាធរតម្កល់អន្តរជាតិបានទទួល (កាលបរិច្ឆេទនៃការផ្ទេរ)

(iv) អត្តសញ្ញាណយោង(លេខ និមិត្តសញ្ញា ។ល។) ដែលអ្នកតម្កល់ផ្តល់ឱ្យ ចំពោះមីក្រូសរីរាង្គ

(v) លេខរៀងដែលផ្តល់ឱ្យដោយអាជ្ញាធរតម្កល់អន្តរជាតិ

(vi) ឈ្មោះ និង អាសយដ្ឋានអាជ្ញាធរតម្កល់អន្តរជាតិដែលទទួលការផ្ទេរ

(vii) លេខរៀងដែលផ្តល់ឱ្យដោយអាជ្ញាធរតម្កល់អន្តរជាតិដែលទទួលការផ្ទេរ

(viii) ការបញ្ជាក់ពីអង្គហេតុនេះ នៅពេលដែល សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងប្រការ៦.១(ក) ឬ ប្រការ៦.២(ក)

មានសេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬ សំណើកំណត់ចំណាត់ថ្នាក់នៃមីក្រូសរីរាង្គ ឬ នៅពេលដែលសេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬសំណើកំណត់ចំណាត់ថ្នាក់ត្រូវបានបង្ហាញ ឬបានធ្វើវិសោធនកម្ម នាពេលក្រោយ តាមប្រការ៨.១ ។

**៧.៦ សេចក្តីជូនដំណឹងនៃសេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬ សំណើកំណត់ចំណាត់ថ្នាក់**

តាមសំណើភាគីណាមួយ ដែលមានសិទ្ធិទទួលគំរូមីក្រូសរីរាង្គ ដែលបានតម្កល់តាមប្រការ១១.១ ប្រការ១១.២ ឬ ប្រការ១១.៣ អាជ្ញាធរតម្កល់អន្តរជាតិត្រូវជូនដំណឹង ទៅភាគីនេះពីសេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬ សំណើកំណត់ចំណាត់ថ្នាក់ថ្មីបំផុតដូចមានចែងក្នុងប្រការ៦.១(ខ) ប្រការ៦.២(ក)(iii) ឬ ប្រការ៨.១(ខ)(iii)។

## ប្រការ ៨

## ការបង្ហាញពេលក្រោយឬវិសោធនកម្មសេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬ សំណើកំណត់ចំណាត់ថ្នាក់

### ៨.១ សេចក្តីជូនដំណឹង

(ក) ទាក់ទងនឹងការតម្កល់មីក្រូសរីរាង្គ នៅពេលដែលសេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬសំណើកំណត់ចំណាត់ថ្នាក់មីក្រូសរីរាង្គមិនត្រូវបានបង្ហាញ អ្នកតម្កល់អាចបង្ហាញនៅពេលក្រោយក៏បាន ឬ នៅពេលដែលបានបង្ហាញរួចហើយ អាចធ្វើវិសោធនកម្មសេចក្តីអធិប្បាយនិង/ឬសំណើកំណត់ចំណាត់ថ្នាក់នេះបាន។

(ខ) ការបង្ហាញនៅពេលក្រោយ ឬ វិសោធនកម្មណាមួយ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ដែលមានហត្ថលេខាអ្នកតម្កល់ ទៅអាជ្ញាធរតម្កល់អន្តរជាតិ និង មាន:

(i) ឈ្មោះ និង អាសយដ្ឋានអ្នកតម្កល់

(ii) លេខរៀងដែលផ្តល់ឱ្យដោយអាជ្ញាធរនេះ

(iii) សេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬសំណើកំណត់ចំណាត់ថ្នាក់មីក្រូសរីរាង្គ

(iv) ក្នុងករណីធ្វើវិសោធនកម្ម សេចក្តីអធិប្បាយបែបវិទ្យាសាស្ត្រនិង/ឬសំណើកំណត់ចំណាត់ថ្នាក់ចុងក្រោយគេ។

### ៨.២ លិខិតបញ្ជាក់

តាមសំណើរបស់អ្នកតម្កល់ ដែលបានធ្វើសេចក្តីជូនដំណឹងមានដូចមានចែងក្នុង

ប្រការ៨.១ អាជ្ញាធរតម្កល់អន្តរជាតិត្រូវប្រគល់ឱ្យអ្នកតម្កល់នូវលិខិតបញ្ជាក់ ដែលបង្ហាញទិន្នន័យដូចមានចែងក្នុងប្រការ៨.១(ខ)(i) ដល់ (iv) និងកាលបរិច្ឆេទទទួលបានសេចក្តីជូនដំណឹងនេះ។

## ប្រការ ៩

## ការរក្សាទុកមីក្រូសរីរាង្គ

### ៩.១ រយៈពេលរក្សាទុក

មីក្រូសរីរាង្គណាមួយដែលបានតម្កល់នៅអាជ្ញាធរតម្កល់អន្តរជាតិ ត្រូវរក្សាទុកដោយមានការយកចិត្តទុកដាក់ ដើម្បីរក្សា មីក្រូសរីរាង្គឱ្យនៅមានជីវិតនិងមិនធ្វើឱ្យខូចគុណភាព ដោយអាជ្ញាធរនេះក្នុងរយៈពេលយ៉ាងហោចណាស់៥(ប្រាំ)ឆ្នាំ បន្ទាប់ពីអាជ្ញាធរទទួលបានសំណើថ្មីបំផុតសុំឱ្យផ្តល់គំរូមីក្រូសរីរាង្គដែលបានតម្កល់ ហើយក្នុងករណីណាក៏ដោយត្រូវរក្សាទុកក្នុងរយៈពេលយ៉ាងហោចណាស់៣០(សាមសិប)ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់ ។

### ៩.២ ការសម្ងាត់

អាជ្ញាធរតម្កល់អន្តរជាតិ មិនត្រូវផ្តល់ព័ត៌មានឱ្យជនណាម្នាក់អំពីការតម្កល់មីក្រូសរីរាង្គណាមួយតាមសន្ធិសញ្ញានេះឡើយ។ ជាងនេះទៅទៀត អាជ្ញាធរនេះមិនត្រូវផ្តល់ព័ត៌មានឱ្យជនណាមួយពាក់ព័ន្ធនឹងមីក្រូសរីរាង្គណាមួយ ដែលបានតម្កល់ជាមួយខ្លួនតាមសន្ធិសញ្ញានេះ លើកលែងតែ អាជ្ញាធរណាមួយ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិទទួលគំរូមីក្រូសរីរាង្គនេះ តាមប្រការ១១ និង អនុលោមតាមលក្ខខណ្ឌដូចគ្នាដូចមានចែងក្នុងប្រការនោះ។

## ប្រការ ១០

## តេស្តពីភាពមានជីវិត និងសេចក្តីអះអាងស្តីពីភាពមានជីវិត

### ១០.១ កាតព្វកិច្ចធ្វើតេស្ត

អាជ្ញាធរតម្កល់អន្តរជាតិ ត្រូវធ្វើតេស្តអំពីភាពមានជីវិតនៃមីក្រូសរីរាង្គនីមួយៗដែលបានតម្កល់ជាមួយខ្លួនៈ

(i) ភ្លាមបន្ទាប់ពីការតម្កល់ណាមួយដូចមានចែងក្នុងប្រការ៦ ឬ ការផ្ទេរណាមួយដូចមានចែងក្នុងប្រការ៥.១

(ii) ក្នុងចន្លោះពេលសមរម្យ ដែលអាស្រ័យលើប្រភេទមីក្រូសរីរាង្គ និងលក្ខខណ្ឌដែលអាចរក្សាទុក ឬ ប្រសិនបើចាំបាច់ ចំពោះហេតុផលបច្ចេកវិទ្យា នៅពេលណាក៏បាន

(iii) នៅពេលណាក៏បាន តាមសំណើរបស់អ្នកតម្កល់ ។

## ១០.២ សេចក្ដីអះអាងស្ដីពីភាពមានជីវិត

(ក) អាជ្ញាធរតម្កល់អន្តរជាតិ ត្រូវចេញសេចក្ដីអះអាងពាក់ព័ន្ធនឹងភាពមានជីវិតនៃមីក្រូសរីរាង្គដែលបានតម្កល់:

(i) ទៅអ្នកតម្កល់ ភ្លាមបន្ទាប់ពីការតម្កល់ណាមួយដូចមានចែងក្នុងប្រការ៦ ឬ ការផ្ទេរណាមួយដូចមានចែងក្នុងប្រការ៥.១

(ii) ទៅអ្នកតម្កល់ តាមសំណើរបស់ខ្លួន នៅពេលណាក៏បានបន្ទាប់ពីការតម្កល់ឬការផ្ទេរ

(iii) ទៅការិយាល័យកម្មសិទ្ធិឧស្សាហកម្មណាមួយ ទៅអាជ្ញាធរផ្សេងទៀត ទៅរូបវន្តបុគ្គលឬនីតិបុគ្គលក្រៅពីអ្នកតម្កល់ ទៅបុគ្គលណាឬទៅអាជ្ញាធរណាដែលគំរូមីក្រូសរីរាង្គត្រូវផ្ដល់ឱ្យតាមប្រការ១១ តាមសំណើរបស់បុគ្គលនោះឬអាជ្ញាធរនោះ នៅពេលផ្ដល់គំរូឬ ក្រោយពេលផ្ដល់គំរូ។

(ខ) សេចក្ដីអះអាងស្ដីពីភាពមានជីវិត ត្រូវបង្ហាញទោះបីជាមីក្រូសរីរាង្គមានជីវិតឬលែងមានជីវិតក៏ដោយ ហើយត្រូវមាន:

(i) ឈ្មោះនិងអាសយដ្ឋានអាជ្ញាធរតម្កល់អន្តរជាតិដែលចេញសេចក្ដីអះអាងនេះ

(ii) ឈ្មោះនិងអាសយដ្ឋានអ្នកតម្កល់

(iii) កាលបរិច្ឆេទដូចមានចែងក្នុងប្រការ៧.៣(iii) ឬ នៅពេលដែលមានការតម្កល់ជាថ្មីឬការផ្ទេរ កាលបរិច្ឆេទថ្មីបំផុតដូចមានចែងក្នុងប្រការ៧.៤(iii) និងប្រការ៧.៥(iii)

(iv) លេខរៀងដែលផ្ដល់ឱ្យដោយអាជ្ញាធរនេះ

(v) កាលបរិច្ឆេទនៃការធ្វើតេស្ត

(vi) ព័ត៌មានទាក់ទងនឹងលក្ខខណ្ឌស្ដីពីការតេស្តពីភាពមានជីវិត ឱ្យតែព័ត៌មាននេះត្រូវបានស្នើឡើងដោយភាគីដែលគេចេញសេចក្ដីអះអាងស្ដីពីភាពមានជីវិតឱ្យ ហើយឱ្យតែលទ្ធផលនៃតេស្តនេះមានភាពអវិជ្ជមាន។

(គ) ពេលអនុវត្តកថាខណ្ឌ(ក)(ii)និង(iii) សេចក្ដីអះអាងស្ដីពីភាពមាជីវិត ត្រូវយោងទៅតេស្តពីភាពមានជីវិតថ្មីបំផុត។

(ឃ) ចំពោះទម្រង់ ភាសា និងការចុះហត្ថលេខា ប្រការ៧.២ ត្រូវអនុវត្តដូចគ្នាផង ដែរ ចំពោះសេចក្តីអះអាងស្តីពីភាពមានជីវិត។

(ង) ពេលអនុវត្តកថាខណ្ឌ(ក)(i)ឬនៅពេលដែល ការិយាល័យកម្មសិទ្ធិឧស្សាហកម្ម បានស្នើសុំ ការចេញសេចក្តីអះអាងស្តីពីភាពមានជីវិត មិនត្រូវគិតកម្រៃឡើយ។ កម្រៃណាមួយតាមប្រការ១២.១(ក)(iii)ទាក់ទងនឹងសេចក្តីអះអាងស្តីពីភាពមានជីវិតណាមួយ ផ្សេងទៀត ត្រូវបង់ដោយភាគីដែលស្នើសុំសេចក្តីអះអាងនេះហើយត្រូវបង់មុនពេលស្នើសុំឬនៅពេលស្នើសុំ។

## ប្រការ ១១

## ការផ្តល់គំរូ

### ១១.១ ការផ្តល់គំរូដល់ការិយាល័យកម្មសិទ្ធិឧស្សាហកម្មពាក់ព័ន្ធ

អាជ្ញាធរតម្កល់អន្តរជាតិណាមួយត្រូវផ្តល់គំរូមីក្រូសរីរាង្គដែលបានតម្កល់ ដល់ការិយាល័យកម្មសិទ្ធិឧស្សាហកម្មនៃរដ្ឋហត្ថលេខី ឬអង្គការកម្មសិទ្ធិឧស្សាហកម្មអន្តររដ្ឋាភិបាលណាមួយ តាមសំណើរបស់ការិយាល័យនេះ ឱ្យតែ សំណើនេះត្រូវមានអមដោយសេចក្តីប្រកាសថា:

(i) សំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម ដែលយោងទៅការតម្កល់មីក្រូសរីរាង្គនេះបានដាក់នៅការិយាល័យ ហើយកម្មវត្ថុនៃ សំណុំលិខិតពាក់ព័ន្ធនឹងមីក្រូសរីរាង្គនេះ ឬ ការប្រើប្រាស់មីក្រូសរីរាង្គនេះ

(ii) សំណុំលិខិតស្នើសុំនេះកំពុងព្យួរទុកនៅឯការិយាល័យនោះ ឬ អាចទទួលប្រកាសនីយបត្រតក្កកម្ម

(iii) ត្រូវការគំរូសម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្ម ដែលមានអានុភាពក្នុងរដ្ឋហត្ថលេខី ឬក្នុងអង្គការ ឬ ក្នុងរដ្ឋជាសមាជិកនៃ អង្គការនេះ

(iv) គំរូនិងព័ត៌មានដែលអម ឬបានពីគំរូនេះ នឹងត្រូវប្រើប្រាស់តែសម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្មខាងលើតែប៉ុណ្ណោះ។

### ១១.២ ការផ្តល់គំរូដល់ ឬដោយមានការអនុញ្ញាតពីអ្នកតម្កល់

អាជ្ញាធរតម្កល់អន្តរជាតិណាមួយ ត្រូវផ្តល់គំរូមីក្រូសរីរាង្គដែលបានតម្កល់ណាមួយ:

(i) ទៅអ្នកតម្កល់ តាមសំណើរបស់ខ្លួន

(ii) ទៅអាជ្ញាធរណាមួយ ឬទៅ រូបវន្តបុគ្គលឬនីតិបុគ្គល(តទៅហៅថាភាគីទទួលបានការអនុញ្ញាត) តាមសំណើរបស់ខ្លួន ឱ្យតែសំណើនេះ

អមដោយសេចក្តីប្រកាសពីអ្នកតម្កល់ដែលអនុញ្ញាតលើសំណើផ្តល់គំរូនេះ។

### ១១.៣ ការផ្តល់គំរូដល់ភាគីដែលមានសិទ្ធស្របច្បាប់

(ក) អាជ្ញាធរតម្កល់អន្តរជាតិណាមួយត្រូវផ្តល់គំរូមីក្រូសរីរាង្គដែលបានតម្កល់ ទៅអាជ្ញាធរណាមួយ ទៅរូបវន្តបុគ្គលឬនីតិបុគ្គល(តទៅហៅថាភាគីមានសិទ្ធិ) តាមសំណើរបស់ភាគីនេះ ឱ្យតែសំណើនេះធ្វើឡើងក្នុងទម្រង់ដែលមាតិកាត្រូវបានកំណត់ដោយសន្និបាត ហើយឱ្យតែក្នុងទម្រង់នេះ ការិយាល័យកម្មសិទ្ធិឧស្សាហកម្មបញ្ជាក់:

(i) ថាសំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម ដែលយោងទៅការតម្កល់មីក្រូសរីរាង្គនេះបានដាក់នៅការិយាល័យ ហើយកម្មវត្ថុនៃ សំណុំលិខិតពាក់ព័ន្ធនឹងមីក្រូសរីរាង្គនេះ ឬ ការប្រើប្រាស់មីក្រូសរីរាង្គនេះ

(ii) លើកលែងតែអនុវត្តឃ្លាទី២ ចំនុច(iii) ថា ការបោះពុម្ពផ្សាយសម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្មត្រូវបានធ្វើឡើង ដោយការិយាល័យនោះ

(iii) ថាភាគីមានសិទ្ធិមានសិទ្ធិលើគំរូមីក្រូសរីរាង្គតាមច្បាប់ដែល គ្រប់គ្រងនីតិវិធីប្រកាសនីយបត្រតក្កកម្ម ចំពោះមុខការិយាល័យនោះ ហើយនៅពេលដែលច្បាប់បញ្ញត្តិឱ្យសិទ្ធិនេះ រណាបទៅនឹងការបំពេញលក្ខខណ្ឌមួយចំនួន ថាការិយាល័យនោះបានបំពេញលក្ខខណ្ឌទាំងនេះរួចរាល់ហើយឬថាភាគីដែលមានសិទ្ធិបានចុះហត្ថលេខាលើ ទម្រង់ចំពោះមុខការិយាល័យនោះ ហើយជាវិបាកនៃការចុះហត្ថលេខាលើទម្រង់នេះថាលក្ខខណ្ឌចំពោះការផ្តល់គំរូទៅភាគីមានសិទ្ធិ ត្រូវចាត់ទុកថាបានបំពេញអនុលោមតាមច្បាប់ដែលគ្រប់គ្រងនីតិវិធីប្រកាសនីយបត្រតក្កកម្មចំពោះមុខការិយាល័យនោះ។ នៅពេលដែលភាគីមានសិទ្ធិ ទទួលបានសិទ្ធិតាមច្បាប់នេះ មុនពេលការិយាល័យនោះបោះពុម្ពផ្សាយសម្រាប់គោលបំណងនីតិវិធីប្រកាសនីយបត្រតក្កកម្ម ហើយប្រសិនការបោះពុម្ពផ្សាយនេះមិនទាន់បានធ្វើ លិខិតបញ្ជាក់ត្រូវចែងឱ្យច្បាស់អំពីរឿងនេះ ហើយត្រូវបង្ហាញបទប្បញ្ញត្តិដែលអនុវត្តនៃច្បាប់ខាងលើ រួមទាំងសេចក្តីសម្រេចរបស់តុលាការដោយធ្វើអគតដ្ឋានអំពីការបោះពុម្ពផ្សាយតាមទម្លាប់។

(ខ) ចំពោះប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ និងបានបោះពុម្ពផ្សាយដោយការិយាល័យកម្មសិទ្ធិឧស្សាហកម្មណាមួយ ការិយាល័យនេះ អាច នៅពេលណាក៏បានជូនដំណឹងទៅអាជ្ញាធរតម្កល់អន្តរជាតិណាមួយនូវបញ្ជីលេខរៀងដែលផ្តល់ឱ្យដោយអាជ្ញាធរនេះពីការតម្កល់មីក្រូសរីរាង្គដូចមានកំណត់ក្នុងប្រកាសនីយបត្រតក្កកម្មនេះ។ តាមសំណើរបស់អាជ្ញាធរ រូបវន្តបុគ្គលឬនីតិបុគ្គលណាមួយ(តទៅហៅថា ភាគីស្នើសុំ ) អាជ្ញាធរតម្កល់អន្តរជាតិ ត្រូវផ្តល់គំរូមីក្រូសរីរាង្គណាមួយនៅពេលដែលលេខរៀងត្រូវបានជូនដំណឹង។ ចំពោះមីក្រូសរីរាង្គដែលបានតម្កល់ ដែលលេខរៀងត្រូវបានជូនដំណឹង ការិយាល័យនេះមិនត្រូវតម្រូវឱ្យផ្តល់វិញ្ញាបនបត្រដូចមានចែងក្នុងប្រការ១១.៣(ក)។

## ១១.៤ ប្រការរួម

(ក) សំណើ សេចក្តីប្រកាស លិខិតបញ្ជាក់ ឬ សេចក្តីជូនដំណឹងណាមួយដូចមានចែងក្នុងប្រការ១១.១ ប្រការ១១.២ និងប្រការ១១.៣ ត្រូវធ្វើ:

(i) ជាភាសា អង់គ្លេស បារាំង រុស្ស៊ី ឬ អេស្ប៉ាញ នៅពេលដែលលិខិតនេះដាក់ទៅអាជ្ញាធរតម្កល់អន្តរជាតិ ដែលមាន ភាសាផ្លូវការណាមួយរបស់ខ្លួន ជាភាសា អង់គ្លេស បារាំង រុស្ស៊ី ឬ អេស្ប៉ាញ។ ប៉ុន្តែនៅពេលដែលត្រូវធ្វើជាភាសារុស្ស៊ី ឬ ភាសាអេស្ប៉ាញ លិខិតនេះអាចដាក់ ជាភាសាអង់គ្លេសឬភាសាបារាំងជាជំនួស ហើយ ប្រសិនបើត្រូវបានដាក់ជាភាសាបារាំងឬអង់គ្លេស តាមសំណើរបស់ភាគីមានប្រយោជន៍ដូចមានចែងក្នុងប្រការនេះឬតាមសំណើ អាជ្ញាធរតម្កល់អន្តរជាតិ ការិយាល័យអន្តរជាតិ ត្រូវធ្វើការបកប្រែ ជាភាសារុស្ស៊ី ឬភាសាអេស្ប៉ាញដែលបញ្ជាក់ថាត្រឹមត្រូវ ភ្លាមដោយមិនគិតកម្រៃ

(ii) ក្នុងករណីផ្សេងទៀត លិខិតនេះត្រូវធ្វើជាភាសាអង់គ្លេស ឬ ភាសាបារាំង។ ប៉ុន្តែលិខិតនេះអាចធ្វើជាភាសាផ្លូវការឬជាភាសាផ្លូវការណាមួយនៃអាជ្ញាធរតម្កល់អន្តរជាតិជំនួសភាសាអង់គ្លេស ឬភាសាបារាំង។

(ខ) ថ្វីបើមានចែងក្នុងកថាខណ្ឌ(ក)ក៏ដោយ នៅពេលដែលសំណើដូចមានចែងក្នុងប្រការ១១.១ ធ្វើឡើងដោយការិយាល័យកម្មសិទ្ធិឧស្សាហកម្មដែលមានភាសាផ្លូវការ ជាភាសារុស្ស៊ី ឬជាភាសាអេស្ប៉ាញ សំណើនេះអាចធ្វើជាភាសារុស្ស៊ី ឬជាភាសាអេស្ប៉ាញតាមករណីនីមួយៗហើយការិយាល័យអន្តរជាតិត្រូវធ្វើការបកប្រែ ជាភាសាអង់គ្លេស ឬ ជាភាសាបារាំងដែលបញ្ជាក់ថាត្រឹមត្រូវ ភ្លាមដោយមិនគិតកម្រៃ តាមសំណើការិយាល័យ ឬអាជ្ញាធរតម្កល់អន្តរជាតិ ដែលទទួលបានសំណើនេះ។

(គ) សំណើ សេចក្តីប្រកាស លិខិតបញ្ជាក់ ឬ សេចក្តីជូនដំណឹងណាមួយដូចមានចែងក្នុង ប្រការ១១.១ ប្រការ១១.២ និងប្រការ១១.៣ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវមានការចុះហត្ថលេខា និងត្រូវមានកាលបរិច្ឆេទ។

(ឃ) សំណើ សេចក្តីប្រកាស ឬ លិខិតបញ្ជាក់ណាមួយដូចមានចែងក្នុង ប្រការ ១១.១ ប្រការ១១.២ និងប្រការ១១.៣(ក) ត្រូវមានការបង្ហាញដូចខាងក្រោម:

(i) ឈ្មោះនិងអាសយដ្ឋានការិយាល័យកម្មសិទ្ធិឧស្សាហកម្មដែលធ្វើសំណើ ភាគីដែលទទួលបានការអនុញ្ញាតឬភាគីដែលមានសិទ្ធិតាមករណីនីមួយៗ

(ii) លេខរៀងដែលផ្តល់ឱ្យការតម្កល់

(iii) ក្នុងករណីនៃប្រការ១១.៣(ក) កាលបរិច្ឆេទ និងលេខសំណុំលិខិតស្នើសុំ ឬប្រកាសនីយបត្រតក្កកម្មដែលបានយោងទៅការតម្កល់

(iv) ក្នុងករណីនៃប្រការ១១.៣(ក) ការបង្ហាញដូចមានចែងក្នុងចំនុច(iii) និងឈ្មោះនិងអាសយដ្ឋានការិយាល័យកម្មសិទ្ធិឧស្សាហកម្ម ដែលបានធ្វើការបញ្ជាក់ដូចមានចែងក្នុងប្រការនោះ

(ង) សំណើណាមួយដូចមានចែងក្នុងប្រការ១១.៣(ក) ត្រូវមានការបង្ហាញដូចខាងក្រោម:

(i) នាម និង អាសយដ្ឋានភាគីស្នើសុំ

(ii) លេខរៀងដែលផ្តល់ឱ្យការតម្កល់

(ច) ឧបករណ៍ផ្ទុកគំរូដែលផ្តល់ឱ្យ ត្រូវចុះលេខរៀងនៃការតម្កល់ ដោយអាជ្ញាធរតម្កល់អន្តរជាតិនិងត្រូវអមដោយច្បាប់ចម្លងនៃបង្កាន់ដៃដូចមានចែងក្នុងប្រការ៧ អមដោយការបង្ហាញលក្ខណៈនៃមីក្រូសរីរាង្គដែលមានឬអាចមានគ្រោះថ្នាក់ដល់សុខ ភាពឬបរិស្ថាន ហើយបើមាន សំណើ ត្រូវអមដោយ ការបង្ហាញលក្ខខណ្ឌដែលអាជ្ញាធរតម្កល់អន្តរជាតិប្រើប្រាស់សម្រាប់ចិញ្ចឹមនិងរក្សាទុកមីក្រូសរីរាង្គ។

(ឆ) អាជ្ញាធរតម្កល់អន្តរជាតិដែលបានផ្តល់គំរូទៅភាគីមានប្រយោជន៍ណាមួយក្រៅពីអ្នកតម្កល់ ត្រូវជូនដំណឹងភ្លាម ដល់អ្នកតម្កល់ ជាលាយលក្ខណ៍អក្សរអំពី អង្គហេតុនេះ ក៏ដូចជាកាលបរិច្ឆេទនៃការផ្តល់គំរូនេះ និង ឈ្មោះនិងអាសយដ្ឋានការិយាល័យកម្មសិទ្ធិឧស្សាហកម្ម ភាគីដែលទទួលបានការអនុញ្ញាត ភាគីដែលមានសិទ្ធិ ឬភាគីស្នើសុំឱ្យផ្តល់គំរូនេះ។ សេចក្តីជូនដំណឹងនេះ ត្រូវអមដោយច្បាប់ចម្លងមួយច្បាប់នៃសំណើពាក់ព័ន្ធនៃសេចក្តីប្រកាសណាមួយដែលបានដាក់តាមប្រការ១១.១ ឬប្រការ ១១.២(ii) ដែលទាក់

ទងនឹងសំណើនេះ និង នៃទម្រង់ឬសំណើណាមួយ ដែលមានចុះហត្ថលេខារបស់ភាគីស្នើសុំដែលអនុលោមតាមប្រការ១១.៣។

(ជ) ការផ្តល់គំរូដូចមានចែងក្នុងប្រការ១១.១ មិនត្រូវគិតកម្រៃទេ។ នៅពេលដែលមានការផ្តល់គំរូតាមប្រការ១១.២ឬ១១.៣ កម្រៃតាមប្រការ១២.១(ក) (iv) ត្រូវបង់ដោយអ្នកតម្កល់ ភាគីដែលទទួលបានការអនុញ្ញាត ភាគីដែលមានសិទ្ធិ ឬ ភាគីស្នើសុំតាមករណីនីមួយៗហើយ ត្រូវបង់មុនពេលធ្វើសំណើឬនៅពេលធ្វើសំណើ។

**១១.៥ កាផ្លាស់ប្តូរប្រការ១១.១ និងប្រការ ១១.៣ ពេលដាក់សំណុំលិខិតស្នើសុំអន្តរជាតិ**

នៅពេលដែលសំណុំលិខិតស្នើសុំមួយ បានដាក់ជាសំណុំលិខិតស្នើសុំអន្តរជាតិតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ការយោងទៅលើការដាក់សំណុំលិខិតស្នើសុំនៅការិយាល័យកម្មសិទ្ធិឧស្សាហកម្មតាមប្រការ១១.១(i) និង ប្រការ១១.៣(ក)(i)ត្រូវចាត់ទុកថាជាការយោងទៅការជ្រើសតាំងការិយាល័យកម្មសិទ្ធិឧស្សាហកម្មជាការិយាល័យជ្រើសតាំងនៃរដ្ឋហត្ថលេខីតាមអត្ថន័យនៃសន្ធិសញ្ញានោះ ក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ ហើយការបញ្ជាក់នៃការបោះពុម្ពផ្សាយដែលទាមទារប្រការ១១.៣(ក)(ii)តាមជម្រើសរបស់ការិយាល័យកម្មសិទ្ធិឧស្សាហកម្ម ត្រូវជាការបញ្ជាក់នៃការបោះពុម្ពផ្សាយអន្តរជាតិតាមសន្ធិសញ្ញានេះ ឬការបញ្ជាក់នៃការបោះពុម្ពផ្សាយដោយការិយាល័យនេះ។

## ប្រការ ១២

## កម្រៃ

### ១២.១ ប្រភេទនិងចំនួន

(ក) ដោយអនុលោមតាមនីតិវិធីនៃសន្ធិសញ្ញានិងបទបញ្ជាទាំងនេះ អាជ្ញាធរតម្កល់អន្តរជាតិណាមួយ អាចគិតកម្រៃៈ

(i) ចំពោះការរក្សាទុក

(ii) ចំពោះការបញ្ជាក់ដូចមានចែងក្នុងប្រការ៨.២

(iii) យោងតាមប្រការ១០.២(ង) ឃ្លាទី១ ចំពោះការចេញសេចក្តីអះអាងស្តីពីភាពមានជីវិត

(iv) យោងតាមប្រការ១១.៤(ជ) ឃ្លាទី១ ចំពោះការផ្តល់គំរូ

(v) ចំពោះសេចក្តីជូនដំណឹងតាមប្រការ៧.៦

(ខ) កម្រៃចំពោះការរក្សាទុក មានសុពលភាពត្រឹមរយៈពេលនៃការរក្សាទុកមីក្រូសរីរាង្គដូចមានចែងក្នុងប្រការ៩.១។

(គ) ចំនួនកម្រៃ មិនត្រូវខុសគ្នាដោយមូលហេតុ សញ្ជាតិឬ លំនៅឋានរបស់អ្នកតម្កល់ ឬដោយមូលហេតុ សញ្ជាតិឬលំនៅឋានរបស់អាជ្ញាធរ រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំឱ្យចេញសេចក្តីអះអាងស្តីពីភាពមានជីវិត ឬសុំឱ្យផ្តល់ផ្តល់គំរូ។

## ១២.២ ការផ្លាស់ប្តូរចំនួន

(ក) ការផ្លាស់ប្តូរចំនួនកម្រៃណាមួយ ដែលកំណត់ដោយអាជ្ញាធរតម្កល់អន្តរជាតិត្រូវជូនដំណឹងទៅអគ្គនាយកដោយរដ្ឋហត្ថលេខី ឬអង្គការអន្តររដ្ឋាភិបាលកម្មសិទ្ធិឧស្សាហកម្មដែលបានធ្វើសេចក្តីប្រកាសដូចមានចែងក្នុងមាត្រា៧(១) ទៅកាន់អាជ្ញាធរនេះ។យោងតាមកថាខណ្ឌ(គ) សេចក្តីជូនដំណឹង អាចមានការបញ្ជាក់កាលបរិច្ឆេទនៃការអនុវត្តកម្រៃថ្មី។

(ខ) អគ្គនាយកត្រូវជូនដំណឹងភ្លាមទៅរដ្ឋហត្ថលេខីនិងអង្គការអន្តររដ្ឋាភិបាលកម្មសិទ្ធិឧស្សាហកម្មទាំងអស់ អំពីសេចក្តីជូនដំណឹងដែលទទួលបានតាមកថាខណ្ឌ(ក) និងកាលបរិច្ឆេទអានុភាពនៃសេចក្តីជូនដំណឹងនេះតាមកថាខណ្ឌ(គ)។ ការិយាល័យអន្តរជាតិត្រូវបោះពុម្ពផ្សាយភ្លាមនូវសេចក្តីជូនដំណឹងរបស់អគ្គនាយក និងសេចក្តីជូនដំណឹងដែលអគ្គនាយកទទួលបាន។

(គ)កម្រៃថ្មីណាមួយ ត្រូវអនុវត្តតាមកាលបរិច្ឆេទ ដែលបានកំណត់តាមកថាខណ្ឌ (ក) ។ នៅពេលដែលការផ្លាស់ប្តូរមានការបង្កើនចំនួនកម្រៃ ឬនៅពេលដែលគ្មានកំណត់កាលបរិច្ឆេទ កម្រៃថ្មីត្រូវអនុវត្តចាប់ពីថ្ងៃទី១៣បន្ទាប់ពីការិយាល័យអន្តរជាតិបានបោះពុម្ពផ្សាយពីការផ្លាស់ប្តូរនេះ។

## ប្រការ ១២ ស្ទួន

## ការគណនារយៈពេលកំណត់

## ១២ ស្ទួន.១ រយៈពេលគិតជាឆ្នាំ

នៅពេលដែលរយៈពេលត្រូវគិតជាមួយឆ្នាំឬច្រើនឆ្នាំ ការគណនាត្រូវរាប់ចាប់ពីថ្ងៃដែលហេតុការណ៍ពាក់ព័ន្ធបានកើតឡើង ហើយរយៈពេលនេះ ត្រូវផុតកំណត់ក្នុងឆ្នាំបន្ទាប់ក្នុងខែដូចគ្នានិងក្នុងថ្ងៃទីដូចគ្នាដូចនឹងខែនិងថ្ងៃទីដែលហេតុការណ៍ខាងលើនេះបានកើតឡើង។ ប្រសិនបើ ខែបន្ទាប់គ្មានថ្ងៃទីដូចគ្នា រយៈពេលនេះត្រូវផុតកំណត់នៅថ្ងៃចុងក្រោយនៃខែនោះ។

## ១២ ស្ទួន. ២ រយៈពេលគិតជាខែ

នៅពេលដែលរយៈពេលគិតជា មួយខែឬច្រើនខែ ការគណនាត្រូវរាប់ចាប់ថ្ងៃដែលហេតុការណ៍ពាក់ព័ន្ធបានកើតឡើង ហើយរយៈពេលនេះ ត្រូវផុតកំណត់ក្នុងខែបន្ទាប់ នា

ថ្ងៃទីដូចគ្នានឹងថ្ងៃទីដែលហេតុការណ៍ខាងលើនេះបានកើតឡើង។ ប្រសិនបើខែបន្ទាប់គ្មានថ្ងៃទីដូចគ្នា រយៈពេលនេះត្រូវផុតកំណត់នៅថ្ងៃចុងក្រោយនៃខែនោះ។

### ១២ ស្ទួន.៣ រយៈពេលគិតជាថ្ងៃ

នៅពេលដែលរយៈពេលគិតជាចំនួនថ្ងៃ ការគណនាត្រូវរាប់ចាប់ពីថ្ងៃ ដែលហេតុការណ៍ពាក់ព័ន្ធបានកើតឡើង ហើយរយៈពេលនេះ ត្រូវផុតកំណត់នៅថ្ងៃដែលជាថ្ងៃចុងក្រោយនៃការគណនា។

## ប្រការ ១៣

## ការបោះពុម្ពផ្សាយដោយការិយាល័យអន្តរជាតិ

### ១៣.១ ទម្រង់នៃការបោះពុម្ពផ្សាយ

ការបោះពុម្ពផ្សាយណាមួយដោយការិយាល័យអន្តរជាតិដូចមានចែងក្នុងសន្ធិសញ្ញា ឬបទបញ្ជាទាំងនេះ ត្រូវធ្វើឡើងក្នុងទម្រង់ក្រដាស ឬ ទម្រង់អេឡិចត្រូនិច។

### ១៣.២ មាតិកា

(ក) បញ្ជីបច្ចុប្បន្នភាពនៃអាជ្ញាធរតម្កល់អន្តរជាតិ ត្រូវបោះពុម្ពផ្សាយ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ជាការល្អក្នុងត្រីមាសទីមួយនៃឆ្នាំ ដោយបង្ហាញចំពោះអាជ្ញាធរនីមួយៗនូវប្រភេទមីក្រូសរីរាង្គដែលអាចតម្កល់ជាមួយខ្លួន និងចំនួនកម្រៃដែលត្រូវបង់ជូនខ្លួន។

(ខ) ព័ត៌មានទាំងមូលនៃអង្គហេតុណាមួយដូចខាងក្រោមត្រូវបោះពុម្ពផ្សាយ តែម្តង ភ្លាមបន្ទាប់ពីអង្គហេតុនេះបានកើតឡើងៈ

(i) ការទទួលបាន ការបញ្ចប់ ឬការកម្រិតឋានៈជាអាជ្ញាធរតម្កល់អន្តរជាតិ និងការចាត់វិធានការ ដែលទាក់ទងនឹងការបញ្ចប់ ឬការកម្រិតនេះ

(ii) ការបន្ត ដូចមានចែងក្នុងប្រការ៣.៣

(iii) ការឈប់បំពេញមុខងារនៃអាជ្ញាធរតម្កល់អន្តរជាតិ ការបដិសេធមិនទទួលយកប្រភេទមីក្រូសរីរាង្គមួយចំនួន និងការចាត់វិធានការ ទាក់ទងនឹងការឈប់បំពេញមុខងារ ឬការបដិសេធនេះ

(iv) ការផ្លាស់ប្តូរណាមួយចំពោះកម្រៃដែលកំណត់ដោយអាជ្ញាធរតម្កល់អន្តរជាតិ

(v)លក្ខខណ្ឌណាមួយដែលបានជូនដំណឹងតាមប្រការ៦.៣(ខ) និងវិសោធនកម្មណាមួយនៃលក្ខខណ្ឌនេះ។

## ប្រការ ១៤

## ការចំណាយនៃគណៈប្រតិភូ

### ១៤.១ មុខចំណាយ

ការចំណាយនៃគណៈប្រតិភូនីមួយៗដែលចូលរួមក្នុងកិច្ចប្រជុំ សន្និបាត និងក្នុងគណៈកម្មាធិការ ក្រុមការងារ ឬ កិច្ចប្រជុំផ្សេងៗទៀត ដែលដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងសហភាពជាបន្ទុករបស់រដ្ឋ ឬ អង្គការដែលចាត់តាំងគណៈប្រតិភូនេះ។

## ប្រការ ១៥

## ការខ្វះកូរ៉ុមក្នុងសន្និបាត

### ១៥.១ ការបោះឆ្នោតពីចម្ងាយ

(ក) ក្នុងករណីដូចមានចែងក្នុងមាត្រា១០(៥)(ខ) អគ្គនាយកត្រូវជូនដំណឹងពីសេចក្តីសម្រេចរបស់សន្និបាត(ក្រៅពីសេចក្តីសម្រេចពាក់ព័ន្ធនឹងនីតិវិធីផ្ទាល់របស់សន្និបាត) ទៅរដ្ឋហត្ថលេខីទាំងឡាយដែលគ្មានវត្តមាននៅពេលធ្វើសេចក្តីសម្រេច ហើយត្រូវអញ្ជើញរដ្ឋហត្ថលេខីទាំងនេះឱ្យបោះឆ្នោតជាលាយលក្ខណ៍អក្សរ ឬបោះឆ្នោតអនុប្បវាទ ក្នុងរយៈពេល៣(បី)ខែបន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង។

(ខ) នៅពេលផុតរយៈពេលនេះ ប្រសិនបើចំនួនរដ្ឋហត្ថលេខីដែលបានបោះឆ្នោត ឬបោះឆ្នោតអនុប្បវាទស្មើនឹងចំនួនរដ្ឋហត្ថលេខី ដែលខ្វះសម្រាប់កូរ៉ុមនៅពេលធ្វើសេចក្តីសម្រេច សេចក្តីសម្រេចនេះអាចនឹងយកមកអនុវត្តបានឱ្យតែបានគ្រប់សំលេងភាគច្រើនដែលតម្រូវ។

---

* ចំនងជើងជាភាសាអង់គ្លេសជាផ្លូវការ។

ចូលជាធរមាន(នៃវិសោធនកម្មចុងក្រោយ(ចំពោះប្រការ ១៣)): ថ្ងៃទី២ ខែតុលា ឆ្នាំ២០០២។

ប្រភពៈការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក

** បន្ថែមដោយការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

[1] ចំពោះអត្ថបទនៃសន្ធិសញ្ញាទីក្រុងប៊ុយដាប៉េស សូមមើលច្បាប់និងសន្ធិសញ្ញាកម្មសិទ្ធិឧស្សាហកម្មសន្ធិសញ្ញាពហុភាគី អត្ថបទ ២-០០៤ (កំណត់សំគាល់របស់អ្នកកែសម្រួល)។